( ៤០ )

# ករណីការអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀលនៅធនាគារ កាណាឌីយ៉ា ក.អ និងសាខាធនាគារ នៅរាជធានី ខេត្ត

លេខ: ២៦៦៣ សហវ.អរគន

ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥២៧ សហវ.អគនរ

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០១៥

## ជម្រាបជូន

## អ្នកឧកញ៉ា ប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ កាណាឌីយ៉ា ក.អ

**កម្មវត្ថុ:** ករណីការអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀលនៅធនាគារ កាណាឌីយ៉ា ក.អ និងសាខាធនាគារនៅរាជធានី ខេត្ត។

**យោង:** អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារ កាណាឌីយ៉ា ក.អ សម្រាប់ប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋអនុវត្តនៅទូទាំងប្រទេស ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៣ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារ កាណាឌីយ៉ា ក.អ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប អ្នកឧកញ៉ា ជ្រាបថា៖ ដើម្បីបង្កើនប្រសិទ្ធភាពសម្រាប់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាតាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការទូទាត់ត្រង់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀលនៅធនាគារ កាណាឌីយ៉ា ក.អ និងសាខាធនាគារនៅរាជធានី ខេត្ត ដូចខាងក្រោម៖

នៅថ្នាក់កណ្តាល៖

- អង្គភាពថវិកានីមួយៗ នៅក្រោមចំណុះក្រសួង ស្ថាប័ន ដែលអនុវត្តថវិកាកម្មវិធី ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការថវិកាកម្មវិធី ហើយប្រធានអង្គភាពថវិកាជាម្ចាស់គណនី។
- សម្រាប់ថវិការបស់ក្រសួង ស្ថាប័ន ដែលអនុវត្តថវិកាកម្មវិធី (ក្រៅពីអង្គភាពថវិកា) ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការថវិកា ហើយរដ្ឋមន្ត្រី ប្រធានស្ថាប័នជាម្ចាស់គណនី។

នៅថ្នាក់រាជធានី ខេត្ត ៖

- មន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការរជ្ជទេយ្យបុរេប្រទាន ហើយប្រធានមន្ទីរជាម្ចាស់គណនី។
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការរជ្ជទេយ្យបុរេប្រទាន ហើយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាម្ចាស់គណនី។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- រដ្ឋបាលឃុំ សង្កាត់ ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការផ្ទេរទេយ្យបុរេប្រទាន ហើយមេឃុំ ចៅសង្កាត់ ជាម្ចាស់គណនី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម អ្នកឧកញ៉ា ជ្រាប និងអនុញ្ញាត តាមការគួរ។

សូម អ្នកឧកញ៉ា ទទួលនូវការគោរពរាប់អាន ពីខ្ញុំ

រដ្ឋមន្ត្រី
ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

ចម្លងជូន:
- *អគ្គនាយកដ្ឋានរតនាគារជាតិ*
- *គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ*
- *រដ្ឋបាលថ្នាក់ក្រោមជាតិ*

  *"ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ ០០៨៤ សហវ.ឧសវ

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១៥

# ជម្រាបជូន

## លោកបណ្ឌិត ប្រធាននាយកប្រតិបត្តិ ធនាគារ អេស៊ីលីដា ភីអិលស៊ី

កម្មវត្ថុ: ករណីការអនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀលនៅធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាខាធនាគារនៅរាជធានី ខេត្ត។

យោង: អនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ប្រតិបត្តិការចំណូល ចំណាយថវិការដ្ឋអនុវត្តនៅទូទាំងប្រទេស ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៣ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគារ អេស៊ីលីដា ភីអិលស៊ី។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប លោកបណ្ឌិត ជ្រាបថា÷ ដើម្បីបង្កើនប្រសិទ្ធភាពសម្រាប់កិច្ចប្រតិបត្តិការចំណូល ចំណាយថវិកាតាមរយៈការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ការទូទាត់ព្រង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុញ្ញាតឱ្យក្រសួង ស្ថាប័ន អង្គភាព មន្ទីរជំនាញ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បើកគណនីចរន្តជាប្រាក់រៀលនៅធនាគារ អេស៊ីលីដា ភីអិលស៊ី និងសាខាធនាគារនៅរាជធានី ខេត្ត ដូចខាងក្រោម÷

នៅថ្នាក់កណ្តាល÷

- អង្គភាពថវិកានីមួយៗ នៅក្រោមចំណុះក្រសួង ស្ថាប័ន ដែលអនុវត្តថវិកាកម្មវិធី ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការថវិកាកម្មវិធី ហើយប្រធានអង្គភាពថវិកាជាម្ចាស់គណនី។
- សម្រាប់ថវិការបស់ក្រសួង ស្ថាប័ន ដែលអនុវត្តថវិកាកម្មវិធី (ក្រៅពីអង្គភាពថវិកា) ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការថវិកា ហើយរដ្ឋមន្ត្រី ប្រធានស្ថាប័នជាម្ចាស់គណនី។

នៅថ្នាក់រាជធានី ខេត្ត ÷

- មន្ទីរជំនាញនៅថ្នាក់រាជធានី ខេត្ត ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទាន ហើយប្រធានមន្ទីរជាម្ចាស់គណនី។
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការរដ្ឋទេយ្យបុរេប្រទាន ហើយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាម្ចាស់គណនី។

St. 92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA

- រដ្ឋបាលឃុំ សង្កាត់ ត្រូវបានអនុញ្ញាតឱ្យបើកគណនីចរន្តជាប្រាក់រៀលចំនួន ០១ (មួយ) សម្រាប់ប្រតិបត្តិការផ្ទេរទេយ្យបុរេប្រទាន ហើយមេឃុំ ចៅសង្កាត់ ជាម្ចាស់គណនី។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកបណ្ឌិត ជ្រាប និងអនុញ្ញាត តាមការគួរ។

សូម លោកបណ្ឌិត ទទួលនូវការគោរពរាប់អាន ពីខ្ញុំ

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

<u>ចម្លងជូន:</u>

- *អគ្គនាយកដ្ឋានរតនាគារជាតិ*
- *គ្រប់ក្រសួង ស្ថាប័ន មន្ទីរជំនាញ*
- *រដ្ឋបាលថ្នាក់ក្រោមជាតិ*
  *"ដើម្បីអនុវត្ត"*
- *ឯកសារ-កាលប្បវត្តិ*

TO: SVP & Head of OD
for letter inform to
OD & all branches.
22/4/2015
G.COO.

Dr. SO PHONNARY